ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អគ្គលេខាធិការដ្ឋាន
លេខ ០២៥ គ.ជ.ប/អគ្គ.ពស

ថ្ងៃចន្ទ ៦រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨

# សេចក្តីប្រកាសព័ត៌មាន
# ការផលិត និងការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

សម្រាប់ការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត នឹងចាប់ផ្តើមពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ដល់ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ ។ យោងតាមសេចក្តីសម្រេចលេខ ១០៩ គ.ជ.ប ស.ស.រ ស្តីពីការផលិត និងការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត មានគោលបំណងកំណត់អំពីការផលិត និងការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ជូនដល់អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ។ ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតត្រូវធ្វើតាមលក្ខណៈបច្ចេកទេសកុំព្យូទ័រ ដោយការផ្ទេរឈ្មោះ និងទិន្នន័យរបស់អ្នកបោះឆ្នោត ចេញពីបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៧ បញ្ចូលនៅក្នុងប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនោះ ។ ប័ណ្ណព័ត៌មានដែលបានផលិតមានរាងចតុកោណ ដែលមានបណ្តោយប្រវែង ៩,៦សង់ទីម៉ែត្រ និងទទឹងប្រវែង ៦,៦សង់ទីម៉ែត្រ ។ នៅផ្នែកខាងមុខនៃប័ណ្ណព័ត៌មាន គឺ ៖

- និមិត្តសញ្ញា គ.ជ.ប
- កាលបរិច្ឆេទ និងពេលវេលានៃការបោះឆ្នោតសកលពាក់ព័ន្ធ
- ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត និងលំនៅឋាន ឬទីសំណាក់នៃអ្នកបោះឆ្នោត លេខរៀងក្នុងបញ្ជីបោះឆ្នោត លេខកូដក្នុងការិយាល័យបោះឆ្នោត និងទីតាំងការិយាល័យបោះឆ្នោត ឈ្មោះឃុំ សង្កាត់ ឈ្មោះរាជធានី ខេត្ត ។

នៅផ្នែកខាងខ្នងនៃប័ណ្ណព័ត៌មាន គឺ ៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ប្រភេទទី១ ឬប្រភេទទី២ ឬប្រភេទទី៣ )
- ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ)

បន្ទាប់ពីបញ្ជីបោះឆ្នោតឆ្នាំ២០១៧ ត្រូវបាន គ.ជ.ប ផ្តល់សុពលភាពរួចមក នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត មានភារកិច្ចយ៉ាងសំខាន់ ក្នុងការផលិតបញ្ជីបោះឆ្នោតផ្លូវការ និងផលិតប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ។

ចំពោះភារកិច្ចរបស់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតមានដូចតទៅ ៖

- ធ្វើទំនាក់ទំនងសហការជាមួយគណៈអភិបាលរាជធានី ខេត្ត និងគណៈអភិបាលក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ដើម្បីផ្តល់ការគាំទ្រចំពោះ គបឃ.ស និងមេភូមិ ឬជំនួយការភូមិឱ្យសហការជាមួយ គឃ.សប ក្នុងការអនុវត្តការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ។

- ចាត់ចែងការផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីការផលិត និងការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងខ្លឹមសារបច្ចេកទេសនៃការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ ជូន គឃ.សប ក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងតំណាងគណបក្សនយោបាយ ។
- បណ្តុះបណ្តាល គឃ.សប អំពីរបៀបចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតជូនអ្នកបោះឆ្នោត ។

រីឯគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតមានតួនាទីត្រូវចាត់តាំងក្រុមចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតមួយ ឬច្រើនក្រុមសមស្របតាមចំនួនភូមិ និងទៅតាមភូមិសាស្ត្រជាក់ស្តែងរបស់ខ្លួន ដែលក្រុមអ្នកចែកប័ណ្ណនេះ មានសមាសភាពដូចតទៅ ៖

| | |
|---|---|
| ១. សមាជិក គឃ.សប ១រូប | ជាប្រធាន |
| ២. សមាជិក គបឃ.ស ១ រូប ឬច្រើនរូប | ជាសមាជិក |
| ៣. តំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ១រូប ឬច្រើនរូប(ប្រសិនបើមាន) | ជាសមាជិក |
| ៤. មេភូមិ ឬជំនួយការភូមិពាក់ព័ន្ធ | ជាសមាជិក |

ចំពោះការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត គធ.ខប ត្រូវ ៖

- ចុះទៅឃុំ សង្កាត់មួយចំនួនក្នុងរាជធានី ខេត្ត ដើម្បីត្រួតពិនិត្យលទ្ធផលនៃការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ក្នុងនោះត្រូវក្តាប់ឱ្យបាននូវចំនួនប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ដែលក្រុមចែកប័ណ្ណព័ត៌មាន និង គឃ.សប បានផ្តល់ជូនប្រជាពលរដ្ឋ និងចំនួនប័ណ្ណព័ត៌មានដែលនៅសល់ (ប្រសិនបើមាន) ។

  ចំពោះប័ណ្ណព័ត៌មានដែលនៅសល់ គឺរក្សាទុកនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ដើម្បីបន្តចែករហូតដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៨ ។
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ក្នុងរាជធានី ខេត្ត ជូន គ.ជ.ប តាមរយៈ អគ្គលេខាធិការដ្ឋាន គ.ជ.ប ។

សូមបញ្ជាក់ផងដែរថា ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនេះ មិនអាចប្រើប្រាស់ជំនួសអត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរ (អ.ខ) ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) ឡើយ ។